# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមហ៊ុនអង្គរសាញឌីវេឡុនមេន (ខាមបូឌា) ខូអិលធីឌី

## កិច្ចព្រមព្រៀង ព្យួរកិច្ចសន្យាការងារ
## កម្មករនិយោជិត បម្រើការងារក្នុងក្រុមហ៊ុន អង្គរសាញ

ឆ្នាំពីរពាន់ម្ភៃ ខែមេសា ថ្ងៃទីប្រាំមួយ វេលាម៉ោងប្រាំបីនិងសាមសិបនាទីនៅក្រុមហ៊ុន **អង្គរសាញ ឌីវេឡុបមេន (ខេមបូឌា) ខូអិលធីឌី** ដែលមានទីតាំងនៅ ភូមិ តាបឹប សង្កាត់ បាវិត ក្រុង បាវិត ខេត្ត ស្វាយរៀង មានរៀបចំកិច្ចប្រជុំស្តីពី ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១៥១ នាក់ ចំនួន ៣៨ ថ្ងៃ ដោយសារក្រុមហ៊ុនខ្វះសម្ភារៈវត្ថុធាតុដើមសម្រាប់ផលិត ទម្ពក់ព្យួរសម្លៀកបំពាក់ និងមិនទាន់មានការបញ្ជាទិញពីអតិថិជន ដោយមានការចូលរួមពីលោកៈ

-លោក LE TRUNG TAN នាយកក្រុមហ៊ុន

-លោក ឡេង គឹមងីម អ្នកបកប្រែ

-លោក វង់ សុង តំណាងកម្មករ

-លោកស្រី ខ្វៃ វណ្ណី តំណាងកម្មករ

-លោក សុខ ជីវ៉ន តំណាងកម្មករ

ក្រោយការពិភាក្សារវាង នាយកក្រុមហ៊ុន និងតំណាងកម្មករ បានបញ្ចប់ភាគីទាំងសងខាងបានព្រមព្រៀង ដូចខាងក្រោម៖

១. ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចំនួន ១៥១ នាក់ ចំនួន ៣៧ ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ២៤ ខែ មេសា រហូតដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២០ ។

២. ក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាកាងារ ក្រុមហ៊ុនបានព្រមព្រៀងផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិត ៤០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរិមាសម្រាប់ឆ្នាំ ២០២០ ។

៣. ក្រុមហ៊ុនព្រមព្រៀងបើកប្រាក់ឧបត្ថម្ភកម្មករនិយោជិត ៤០% នៃ ១៩០ ដុល្លារអាមេរិកដែលជាប្រាក់ឈ្នួលអប្បបរិមាសម្រាប់ឆ្នាំ ២០២០ ជូនកម្មករនិយោជិតនៅថ្ងៃទី ០៥ នៃខែបន្ទាប់ និងបើកនៅក្រុមហ៊ុនផ្ទាល់តែម្តង ។

**នាយកក្រុមហ៊ុន** **ស្នាមមេដៃ តំណាងកម្មករ**

ANGKOR SHINE DEVELOPMENT (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

វង់ សុង ខ្វៃ វណ្ណី សុខ ជីវ៉ន